# ជំនួយស្មារតី
## ពិធីផ្សព្វផ្សាយសារាចរណែនាំ
## ស្តីពី
## វិធានការចាំបាច់នានាក្នុងការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ

ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦

- ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន
- ឯកឧត្តមនាយឧត្តមសេនីយ៍ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ
- ឯកឧត្តមនាយឧត្តមសេនីយ៍ អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ
- ឯកឧត្តមនាយឧត្តមសេនីយ៍ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ
- ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល
- ឯកឧត្តមប្រធានក្រុមប្រឹក្សា និងឯកឧត្តមអភិបាលរាជធានី ខេត្ត
- ឯកឧត្តម លោកជំទាវ លោក លោកស្រីតំណាងក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាលកម្ពុជា
- លោក លោកស្រីតំណាងសហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិលពាក់ព័ន្ធនានា

## I. សេចក្តីផ្តើម

- ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក !
- ផ្អែកតាមមតិដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ថ្ងៃនេះក្នុងនាមក្រសួងមហាផ្ទៃ និងក្នុងនាម **គ.ជ.អ.ប** និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ដែលបានអញ្ជើញមកចូលរួម**ពិធីផ្សព្វផ្សាយ**នាព្រឹកនេះ។
- គោលបំណងសំខាន់នៃពិធីនាព្រឹកនេះ គឺការផ្សព្វផ្សាយខ្លឹមសារនៃ**សារាចរណែនាំស្តីពីវិធានការចាំបាច់នានាក្នុងការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ** ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល នាថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦កន្លងទៅថ្មីៗនេះ ជូនដល់ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ត្រីមានសមត្ថកិច្ច តំណាងសហគមន៍មូលដ្ឋាន និងអង្គការ